# វគ្គទី ២
# គោលការណ៍ច្បាប់បរិស្ថាននៅក្នុងប្រទេសកម្ពុជា

ធ្វើបទបង្ហាញដោយៈ លោក ចាយ ច័ន្ទតារាវណ្ណ
ចៅក្រម និងក្រុមការងារបច្ចេកទេស

# គោលការណ៍ច្បាប់បរិស្ថាន

- ការធ្វើបទបង្ហាញនេះ នឹងពិនិត្យទៅលើគោការណ៍សំខាន់ៗនៃច្បាប់បរិស្ថាន ដែលពាក់ព័ន្ធទៅនឹងប្រទេសកម្ពុជា
- ក្រមបរិស្ថាន និងធនធានធម្មជាតិ ចែងអំពីគោលការណ៍ទូទៅចំនួន ១៣
- មូលដ្ឋានផ្លូវច្បាប់៖ អនុសញ្ញាអន្តរជាតិ

- បញ្ជីអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជា គឺជាហត្ថលេខី៖
  - កិច្ចព្រមព្រៀងអាស៊ាន ស្តីពីការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន
  - កិច្ចព្រមព្រៀងស្តីពីការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល
  - អនុសញ្ញាក្របខ័ណ្ឌនៃសហប្រជាជាតិ ស្តីពីការផ្លាស់ប្តូរអាកាសធាតុ
  - អនុសញ្ញា ស្តីពីតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិ ពិសេសជាជម្រកសត្វស្លាបទឹក
  - អនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីកិច្ចការស្រទាប់អូហ្សូន ២២ មិនា ១៩៨៥
  - អនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យចលនា ដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន
  - អនុសញ្ញាស្តុកខូម ស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ

- អនុសញ្ញា ស្តីពីជីវចម្រុះ
- ពិធីសារក្យូតូនៃអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ
- ពិធីសារ ម៉ុងរ៉េអាល់ ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន
- វិសោធនកម្មចំនួនបួននៃពិធីសារ ម៉ុងរ៉េអាល់ ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន
- ពិធីសារ កាតាហ្សេណា ស្តីពីជីវសុវត្ថិភាពនៃអនុសញ្ញាស្តីពីជីវៈចម្រុះ
- ពិធីសារបន្ថែម ណាហ្គោយ៉ា-កូឡាឡាំពួរ-ពិធីសារកាតាហ្សេណា ស្តីពីការទទួលខុសត្រូវផ្នែកច្បាប់ និងសំណងការខូចខាតទៅនឹងពិធីសារកាតាហ្សេណា ស្តីពីជីវសុវត្ថិភាព
- ពិធីសារ ណាហ្គូយ៉ាធនធានសេនេទិកនៃអនុសញ្ញាស្តីពីជីវៈចម្រុះ
- អនុសញ្ញា ស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះ (អនុសញ្ញាសាយតេស)

# គោលការណ៍ច្បាប់បរិស្ថាន

- គោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តភាព
- គោលការណ៍នៃការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មានបរិស្ថាន និងយុត្តិធម៌
- គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល
- គោលការណ៍ប្រុងប្រយ័ត្នជាមុន
- គោលការណ៍នៃការទប់ស្កាត់
- គោលការណ៍នៃការធ្វើការសម្រេចចិត្តដោយផ្អែកលើភស្តុតាង
- គោលការណ៍សមធម៌រវាងជំនាន់បច្ចុប្បន្ន និងអនាគត



# ការអភិវឌ្ឍប្រកបដោយនិរន្តរភាព

- នៅឆ្នាំ១៩៩២ ក្នុងសន្និសីទរបស់អង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍ (UNCED) សហគមន៍អន្តរជាតិបានទទួលស្គាល់ថា ការអភិវឌ្ឍប្រកបដោយនិរន្តភាពគឺជាគំរូដ៏សំខាន់សម្រាប់ការធ្វើឲ្យប្រសើរឡើងនូវគុណភាពជីវិត ។
- គោលការណ៍ទី៤ នៃសេចក្តីប្រកាសរ៉ាយអូ (Rio) ថែងថា៖

  "ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយនិរន្តភាព ការការពារបរិស្ថានត្រូវបង្កើតដោយច្បាប់ជាផ្នែកសំខាន់មួយនៃដំណើរការនៃការអភិវឌ្ឍ និងមិនអាចត្រូវបានគិតគូរ ដាច់ចេញពីការអភិវឌ្ឍបានឡើយ ។"

# គោលការណ៍នៃការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មាន និងយុត្តិធម៌

- គោលការណ៍នៃការចូលរួមជាសាធារណៈ ផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋានក្នុងការគិត ឬបញ្ចេញមតិ និងក្នុងការស្វែងរក ទទួល និងចែកចាយគំនិត ។
- បុគ្គលនីមួយៗ (ជាពិសេសស្ត្រី) សហជីព អង្គការមិនមែនរដ្ឋាភិបាល ក្រុមហ៊ុនអាជីវកម្ម និងសង្គមស៊ីវិលផ្សេងទៀត អាចចូលរួមយ៉ាងសកម្មក្នុងការធ្វើការសម្រេចចិត្តនៅថ្នាក់ជាតិ និងអន្តរជាតិ ។

# គោលការណ៍នៃការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មាន និងយុត្តិធម៌

- គោលការណ៍នៃការចូលរួមជាសាធារណៈ នៅក្នុងបញ្ហាទាក់ទងនឹងបរិស្ថាន អាចត្រូវបានបង្កើតមិនត្រឹមតែជាសិទ្ធមនុស្សប៉ុណ្ណោះទេ ប៉ុន្តែជាមូលដ្ឋានគ្រឹះមួយនៅក្នុងដំណើរនៃការធ្វើការសម្រេចចិត្ត ។
- គោលការណ៍ទី១០ នៃសេចក្តីប្រកាសរ៉ាយអូ (Rio) ចែងអំពីធាតុផ្សំសំខាន់ៗសម្រាប់អភិបាលកិច្ចល្អនៅក្នុងសិទ្ធិនៃការទទួលបាន ចំនួន៣៖ ទី១ ការទទួលបានព័ត៌មាន ទី២ ការចូលរួមជាសាធារណៈ ទី៣ ការទទួលបានយុត្តិធម៌ ។

# គោលការណ៍នៃការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មាន និងយុត្តិធម៌

- ការទទួលបានព័ត៌មាន លើកកម្ពស់៖
  - ភាពបើកចំហ និងតម្លាភាពនៅក្នុងការធ្វើការសម្រេចចិត្ត
  - បទប្បញ្ញត្តិពាក់ព័ន្ធនឹងបរិស្ថាន ប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាព
- ការទទួលបានព័ត៌មាន ពង្រឹង និងលើកទឹកចិត្តទៅដល់ប្រជាពលរដ្ឋក្នុងការចូលរួម ដោយមានការជូនព័ត៌មានគ្រប់ជ្រុងជ្រោយ និងមានអត្ថន័យ ។
- ការធ្វើការសម្រេចចិត្តដែលមានការចូលរួមពីអ្នកពាក់ព័ន្ធ បង្កើនសមត្ថភាពអង្គភាពរដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងកង្វល់ និងតម្រូវការរបស់សាធារណជន ធ្វើឲ្យមាននូវការយល់ព្រមគ្នា និងការទទួលយក និងការអនុលោមតាមការសម្រេចចិត្តនានាពាក់ព័ន្ធនឹងបរិស្ថាន ពីព្រោះប្រជាពលរដ្ឋ មានអារម្មណ៍ថាពួកគាត់មានភាពជាម្ចាស់ទៅលើការសម្រេចចិត្តទាំងនេះ ។

# គោលការណ៍នៃការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មាន និងយុត្តិធម៌

- ការទទួលបានយុត្តិធម៌
  - ការការពារសិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិក្នុងការចូលរួម
  - ការចោទសួរទៅលើការសម្រេចចិត្តនានា
  - ស្ថាប័នស្របច្បាប់មានសមត្ថកិច្ចក្នុងការពារសិទ្ធិពាក់ព័ន្ធនឹងបរិស្ថាន
  - ដំណើរការតុលាការដែលឯករាជ្យ និងរហ័សសម្រាប់ការខូចខាតបរិស្ថាន
- ការទទួលបានយុត្តិធម៌ សម្រួលទៅដល់សមត្ថភាពរបស់សាធារណៈជនក្នុងការពង្រឹងការអនុវត្តសិទ្ធិរបស់ពួកគាត់ក្នុងការចូលរួម ការជូនព័ត៌មានគ្រប់ជ្រុងជ្រោយ និងធ្វើឲ្យនិយ័តករ និងអ្នកបំពុលមានការទទួលខុសត្រូវចំពោះការខូចខាតបរិស្ថាន ។



# គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល

- គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុលចែងថា ជនណាមួយក៏ដោយ ដែលទទួលខុសត្រូវចំពោះការខូចខាតទៅលើបរិស្ថាន ត្រូវទទួលបន្ទុកលើការចំណាយទាំងឡាយដែលទាក់ទងនឹងការខូចខាតនោះ ។
- ប្រវត្តិនៃគោលការណ៍៖
  - គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល ត្រូវបានលើកឡើងជាលើកដំបូងនៅក្នុងអនុសាសន៍នៃអង្គការសម្រាប់ការសហការ និងការអភិវឌ្ឍសេដ្ឋកិច្ច (OECD) កាលពីថ្ងៃទី ២៦ ខែឧសភា ឆ្នាំ១៩៧២ ។
  - នៅឆ្នាំ ១៩៩២ ក្នុងសេចក្តីប្រកាសរ៉ាយអូ (Rio) គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល មានចែងក្នុងគោលការណ៍ទី១៦ នៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍ ។
- បច្ចុប្បន្ននេះ គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល ត្រូវបានយល់ក្នុងលក្ខណៈទូលំទូលាយ៖
  - គ្រប់ដណ្តប់លើវិធានការក្នុងការទប់ស្កាត់ និងការត្រួតពិនិត្យការបំពុល ។
  - គ្រប់ដណ្តប់លើការទទួលខុសត្រូវចំពោះការចំណាយលើការសម្អាត ចំពោះការខូចខាតបរិស្ថាន ។
  - គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល គឺជាគោលការណ៍សំខាន់មួយនៃការទទួលខុសត្រូវផ្នែកបរិស្ថាន ។ គោលការណ៍នេះ ទាក់ទងគ្នាទៅនឹងការទទួលខុសត្រូវដែលមានលក្ខណៈតឹងរ៉ឹង ។

# គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល

*ក្រុមប្រឹក្សាបណ្តឹងបរិស្ថានឥណ្ឌាប្រឆាំងនឹងសហភាពឥណ្ឌា* (1996) 2JT (SC) 16 ។ តុលាការកំពូលនៃប្រទេសឥណ្ឌា បានអង្កេតក្នុងការពិចារណាទៅលើគោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល ។

> *"យើងគិតថា គោលការណ៍ណាដែលបង្កើតឡើងក្នុងន័យនេះគួរតែសាមញ្ញ ជាក់ស្តែង និងសាកសមទៅនឹងលក្ខខណ្ឌដែលទទួលយកនៅក្នុងប្រទេសនេះ"* ។

# គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល

*ក្រុមប្រឹក្សាបណ្ដឹងបរិស្ថានឥណ្ឌាប្រឆាំងនឹងសហភាពឥណ្ឌា* (1996) 2JT (SC) 16៖ (1996 AIR SCW 1069) ។

*នៅពេលដែលសកម្មភាពដែលបានអនុវត្ត មានគ្រោះថ្នាក់ ឬគ្រោះថ្នាក់ផ្ទាល់ខ្លួន បុគ្គលដែលអនុវត្តសកម្មភាពនោះ ត្រូវទទួលខុសត្រូវឲ្យបានល្អ ចំពោះការបាត់បង់ដែលបានបង្កចំពោះបុគ្គលដទៃទៀត ដោយមិនគិតពីការយកចិត្តទុកដាក់របស់បុគ្គលនោះក្នុងពេលអនុវត្តសកម្មភាពនោះឡើយ ...*

*គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល ដូចបានបកស្រាយដោយតុលាការនេះ មានន័យថាការទទួលខុសត្រូវដាច់ខាតចំពោះការខូចខាតទៅលើបរិស្ថាន រួមមានមិនត្រឹមតែសំណងចំពោះជនរងគ្រោះ ប៉ុន្តែការចំណាយលើថ្លៃស្តារឡើងវិញនូវការខូចខាតបរិស្ថានផងដែរ ។*

# គោលការណ៍ប្រុងប្រយ័ត្នជាមុន

- ប្រុងប្រយ័ត្នជាមុន៖ គួរតែចាត់វិធានការ ដើម្បីបញ្ចៀសហានិភ័យនៃការខូចខាត ទោះបីជាមានភាពខ្វះខាតនៃភាពច្បាស់លាស់នៃការខូចខាតក៏ដោយ
- គោលការណ៍ទី១៥ នៃសេចក្ដីប្រកាសរ៉ាយអូ (Rio) ៖

  " ដើម្បីការពារបរិស្ថាន វិធីសាស្ត្រប្រុងប្រយ័ត្នជាមុន ត្រូវអនុវត្តឲ្យបានទូលំទូលាយ ដោយហត្ថលេខីទាំងឡាយ ទៅតាមសមត្ថភាពរបស់ខ្លួន ។ ក្នុងករណីដែលមានការគំរាមកំហែងនៃការការខូតខាតដែលធ្ងន់ធ្ងរ ឬមិនអាចជួសជុលបាន កង្វះខាតនៃភាពច្បាស់លាស់ផ្នែកវិទ្យាសាស្ត្រពេញលេញ មិនត្រូវបានប្រើប្រាស់ជាហេតុផលសម្រាប់ការពន្យារពេលលើការចំណាយ ដែលជាការចាត់វិធានការប្រកបដោយប្រសិទ្ធភាពក្នុងការទប់ស្កាត់ការខូចខាតបរិស្ថាន" ។

# គោលការណ៍ប្រុងប្រយ័ត្នជាមុន

- មាត្រា៣ នៃអនុសញ្ញាក្របខ័ណ្ឌនៃសហប្រជាជាតិ ស្តីពីការផ្លាស់ប្តូរអាកាសធាតុ៖

  “ភាគី គួរតែចាត់វិធានការប្រុងប្រយ័ត្នជាមុនដើម្បីគិតទុកជាមុន ទប់ស្កាត់ ឬកាត់បន្ថយបុព្វហេតុនៃការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយឥទ្ធិពលជាអវិជ្ជមានរបស់វា ។ ក្នុងករណីដែលមានការគំរាមកំហែងនៃការខូតខាតដែលធ្ងន់ធ្ងរ ឬមិនអាចជួសជុលបាន កង្វះខាតនៃភាពប្រាកដប្រជាផ្នែកវិទ្យាសាស្រ្តពេញលេញ មិនគួរត្រូវបានប្រើប្រាស់ជាហេតុផលសម្រាប់ការពន្យារពេលក្នុងការចាត់វិធានការទាំងនោះ ដើម្បីដោះស្រាយការផ្លាស់ប្តូរអាកាសធាតុ ប៉ុន្តែគួរតែការចំណាយប្រកបដោយប្រសិទ្ធភាព ដើម្បីធានាផលចំណេញជាសកលនៅក្នុងការចំណាយដែលទាបបំផុតដែលអាចធ្វើទៅបាន” ។

# គោលការណ៍នៃការទប់ស្កាត់

- ជាញឹកញយ មិនអាចកើតឡើងទេក្នុងការដោះស្រាយការខូតខាតបរិស្ថាន (ស្ថានភាពដែលមិនអាចជួសជុលបាន)
- ការទប់ស្កាត់៖ គួរតែចាត់វិធានការដើម្បីទប់ស្កាត់ការខូចខាត (នៅមុនពេលការខូចខាតបានកើតឡើង)
- កាតព្វកិច្ចនៃការទប់ស្កាត់ រំលេចពីការទទួលខុសត្រូវ ជាអន្តរជាតិផងដែរ ដែលមិនបង្កឲ្យមានការខូចខាតគួរឲ្យកត់សម្គាល់ទៅលើបរិស្ថានក្រៅដែនដី ប៉ុន្តែវិធីសាស្ត្រទប់ស្កាត់ រិះរកការចៀសវាងនូវការខូចខាត ដោយមិនគិតដល់ថា មានផលប៉ះពាល់ឆ្លងដែន ឬមិនមាននោះទេ ។

# គោលការណ៍នៃការទប់ស្កាត់

- ប្រវត្តិ៖ "សំណុំរឿងរោងចក្ររំលាយលោហៈក្នុងភូមិTrial"៖
- អង្គហេតុនៃសំណុំរឿង៖

ភូមិTrail ស្ថិតនៅខេត្តBritish Columbia ប្រទេសកាណាដា ជិតព្រំប្រទល់សហរដ្ឋអាមេរិច ។ នៅទីកន្លែងនេះ មានរោងចក្ររំលាយលោហៈមួយស្ថិតនៅទីតាំងដែលស័ង្កសី និងសំណ ត្រូវបានរំលាយក្នុងបរិមាណធំតាំងពីឆ្នាំ១៨៩៦ ។ នៅពេលដែលសេចក្តីសម្រេចត្រូវបានអនុវត្តស្ពាន់ធ័រឌីអុកស៊ីតប្រមាណពី៥ ទៅ៧ពាន់តោន ត្រូវបានបញ្ចេញជារៀងរាល់ខែ ដែលបង្កការខូចខាតធ្ងន់ធ្ងរទៅដល់កសិកម្ម ព្រៃឈើ និងទ្រព្យសម្បត្តិឯកជននៅសហរដ្ឋអាមេរិច ។

# គោលការណ៍នៃការទប់ស្កាត់

- តុលាការមជ្ឈត្តករ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៤១៖ សេចក្តីសម្រេចដែលបានអនុវត្តដោយតុលាការ គឺថាមានគោលការណ៍មួយនៃច្បាប់អន្តរជាតិដែលមានការទទួលខុសត្រូវរបស់ប្រទេសមួយ ចំពោះការខូចខាតបរិស្ថានដែលបានបង្កទៅដល់ប្រទេសដទៃទៀត ។
- គោលការណ៍ទី២១ នៃសេចក្តីប្រកាសអនុសញ្ញាស្តុកខូម ឆ្នាំ១៩៧២៖

  "ប្រទេសមានសិទ្ធិជាអធិបតេយ្យ ក្នុងការធ្វើអាជីវកម្មធនធានរបស់ខ្លួន យោងទៅតាមគោលនយោបាយបរិស្ថាន និងការអភិវឌ្ឍរបស់ខ្លួន និងការទទួលខុសត្រូវ ដើម្បីធានាថាសកម្មភាពនៅក្នុងសមត្ថកិច្ច ឬការគ្រប់គ្រងរបស់ខ្លួន មិនបង្កការខូចខាតទៅដល់បរិស្ថាននៃប្រទេសដទៃទៀត ឬតំបន់ដែលហួសដែនកំណត់នៃសមត្ថកិច្ចជាតិ" ។
- គោលការណ៍ទី២ នៃសេចក្តីប្រកាសរ៉ាយអូ (Rio) ឆ្នាំ២០០២ អះអាងជាថ្មី ចំពោះចំណុចនេះ ។
- បច្ចុប្បន្ននេះ មានជាអាទិ៍ប្រទេសដទៃទៀត ប៉ុន្តែដើម្បីទប់ស្កាត់ការខូខខាត មុនពេលវាកើតឡើងទាំងនៅក្នុង និងនៅក្រៅព្រំដែននៃប្រទេសទាំងនោះ ។

# គោលការណ៍នៃការទប់ស្កាត់

- *វេទិកាសុខុមាលរបស់ប្រជាពលរដ្ឋទីក្រុងVelloreប្រឆាំងនឹងសហភាពឥណ្ឌា* AIR (1996 SC 2715) ដើមបណ្ដឹងបានដាក់ពាក្យបណ្ដឹងទាក់ទងនឹងប្រយោជន៍សាធារណៈ ក្រោមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញប្រទេសឥណ្ឌា ប្រឆាំងនឹងការបំពុលដែលបានបង្កដោយការបញ្ចេញសំណល់រាវយ៉ាងធំសម្បើមដែលមិនបានធ្វើប្រព្រឹត្តកម្ម ដោយកន្លែងសំលាប់ស្បែក និងឧស្សាហកម្មផ្សេងទៀតនៅក្នុងរដ្ឋTamil Nadu ។ តុលាការកំពូលប្រទេសឥណ្ឌា បានកត់សម្គាល់ថា៖

"*ទោះបីជាឧស្សាហកម្មកែច្នៃស្បែក មានសារៈសំខាន់ចំពោះប្រទេស ពីព្រោះវាបង្កើតឲ្យមានការដោះដូរជាអន្តរជាតិ និងផ្ដល់មធ្យោបាយការងារ ប៉ុន្តែវាពុំមានសិទ្ធិក្នុងការបំផ្លាញអេកូឡូស៊ី ធ្វើឲ្យខូចបរិស្ថាន និងបង្កគ្រោះថ្នាក់ដល់សុខភាពឡើយ*" ។

# ការទប់ស្កាត់ និងការប្រុងប្រយ័ត្នជាមុន

| ការទប់ស្កាត់ | ការប្រុងប្រយ័ត្នជាមុន |
|---|---|
| ចំណេះដឹងដែលផ្អែកលើហានិភ័យ អាចត្រូវបានគណនា | ភាពមិនប្រាកដប្រជា៖ ហានិភ័យ មិនអាចត្រូវបានគណនា |
| គ្រោះថ្នាក់ | ហានិភ័យ |
| ការខូចខាតអាចកើតមានឡើង ប្រសិនបើមិនចាត់វិធានការ | ការកើតឡើងនៃការខូចខាត មិនមានភាពប្រាកដប្រជា និងមិនអាចព្យាករណ៍បានច្បាស់លាស់ |
| ក្របខ័ណ្ឌក្នុងការធ្វើនិយ័តកម្ម កំណត់លក្ខណៈវិនិច្ឆ័យសំខាន់ ឧទាហរណ៍ ការបំភាយនានា | និយ័តកម្មតាមរយៈលក្ខខណ្ឌតម្រូវនីតិវិធី |
| និយមន័យនៃហានិភ័យដែលអាចទទួលយកបានគឺផ្អែកលើវិទ្យាសាស្ត្រជាបឋម ។ | ការទទួលយកបានខាងផ្នែកសង្គមនៃហានិភ័យគឺត្រូវបានពិចារណា ។ |

# គោលការណ៍សមធម៌រវាងជំនាន់បច្ចុប្បន្ន និងអនាគត

• សមធម៌រួមបញ្ចូលទាំង "សមធម៌ជំនាន់អនាគត" (ឧ. សិទ្ធិនៃជំនាន់អនាគតក្នុងការអាស្រ័យផលមរតករួមក្នុងកម្រិតមួយប្រកបដោយយុត្តិធម៌) និង "សមធម៌ជំនាន់បច្ចុប្បន្ន" (ឧ. សិទ្ធិរបស់មនុស្សជំនាន់បច្ចុប្បន្នក្នុងការទទួលបាននូវការផ្តល់សិទ្ធិទទួលបានធនធានធម្មជាតិរបស់ជំនាន់បច្ចុប្បន្នប្រកបដោយយុត្តិធម៌) ។

# ប្រឡាយទឹកដែលហូរចូលទៅក្នុងកំពង់ផែ

## Manila Bay



- តុលាការជាតិមួយចំនួន បានសំដៅទៅលើសិទ្ធិនៃជំនាន់អនាគតនៅក្នុងករណីទាំងឡាយចំពោះមុខពួកគេ ។ ជាឧទាហរណ៍ តុលាការកំពូលនៃសាធារណរដ្ឋហ្វីលីពីន បានសម្រេចនៅក្នុង*ករណី Minors Oposa* (ហ្វីលីពីន - Oposa et. al. v. Fulgencio S. Factoran, Jr. et al. G.R. លេខ 101083) ថាដើមបណ្ដឹង អាចដាក់ពាក្យបណ្ដឹងតំណាងមួយ សម្រាប់បុគ្គលផ្សេងទៀតនៃជំនាន់របស់ពួកគេ និងសម្រាប់ជំនាន់អនាគត ។ តុលាការដោយមានការពិចារណាទៅលើទស្សនៈនៃការទទួលខុសត្រូវចំពោះជំនាន់អនាគត បានថ្លែងបន្ថែមថា**រាល់គ្រប់ជំនាន់ មានការទទួលខុសត្រូវចំពោះជំនាន់អនាគត ដើម្បីរក្សាទុកនូវភាពស៊ីសង្វាក់ និងភាពសុខដុមដែលចាំបាច់សម្រាប់ការអាស្រ័យផលពេញលេញនៃអេកូឡូស៊ីដែលមានតុល្យភាព និងមានសុខភាពល្អ ។**

# គោលការណ៍នៃការធ្វើការសម្រេចចិត្ត ដោយផ្អែកលើភស្តុតាង

- ការធ្វើការសម្រេចចិត្តដែលទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានតម្លាភាព និងផ្អែកលើភស្តុតាងដោយប្រើប្រាស់ព័ត៌មានដែលអាចស្វែងរកបាន និងប្រសើរបំផុត ។ ព័ត៌មាននេះ អាចមានលក្ខណៈវិទ្យាសាស្ត្រ និងបច្ចេកទេស និងអាចត្រូវបានប្រមូលចេញពីការយល់ដឹងរបស់សហគមន៍ និងជនជាតិដើមភាគតិច ។

- **គោលការណ៍ សមភាពយេនឌ័រក្នុងការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ**

សមធម៌យេនឌ័រនិងការចូលរួមរបស់ស្ត្រីនៅក្នុងរាល់ទិដ្ឋភាពទាំងអស់ទាក់ទងនឹងការសម្រេចចិត្តអំពីបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលបាននូវការលើកកម្ពស់និងការលើកទឹកចិត្ត ។

- **គោលការណ៍ ប្រយោជន៍សាធារណៈ**

ផលប្រយោជន៍សាធារណៈត្រូវមានឧត្តមភាពជាប្រយោជន៍បុគ្គលឯកជន ឬ នីតិបុគ្គលឯកជន នៅក្នុងគ្រប់ការសម្រេចចិត្តទាំងអស់ ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។

- **គោលការណ៍សមាហរណកម្មឬការបញ្ជ្រាប**

គោលបំណងនៃការការពារបរិស្ថាន និងការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព ត្រូវដាក់បញ្ចូលទៅក្នុងការ រៀបចំផែនការអភិវឌ្ឍ និងការធ្វើការសម្រេចចិត្តដែល តម្រូវឲ្យមានការដាក់បញ្ចូលនូវការការពារបរិស្ថាន ការ អភិវឌ្ឍសេដ្ឋកិច្ច និងសិទ្ធិខាងផ្នែកបរិស្ថាន ទៅក្នុង ដំណាក់កាលផ្តួចផ្តើមដំបូងនៃការធ្វើច្បាប់ និងគោល នយោបាយ និងដំណាក់កាលនៃការអនុវត្តគោល នយោបាយ និងច្បាប់ផងដែរ។

- **គោលការណ៍ អ្នកប្រើប្រាស់ជាអ្នកបង់ថ្លៃ**

អ្នកប្រើប្រាស់ធនធានធម្មជាតិ ត្រូវបង់ថ្លៃចំណាយដោយផ្ទាល់ ឬប្រយោល សម្រាប់ការប្រើប្រាស់ ឬផលប៉ះពាល់ដែលកើតចេញពីការប្រើប្រាស់ធនធានធម្មជាតិ ។

- **គោលការណ៍ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ សម្រាប់សហគមន៍ជនជាតិដើមភាគតិច**

សកម្មភាព ឬ គម្រោងដែលស្នើសុំ ដែលអាចប៉ះពាល់ដល់ដីធ្លី ឬធនធានដទៃទៀត ជា ពិសេស ដែលទាក់ទងទៅនឹងការអភិវឌ្ឍ ការប្រើប្រាស់ និងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ត្រូវទទួលនូវការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ របស់ជនជាតិដើមភាគតិច ។

# សូមអរគុណ!!!